ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤

# សេចក្តីប្រកាសព័ត៌មាន
# អង្គជំនុំជម្រះតុលាការកំពូលតម្កល់
# សេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២

នៅថ្ងៃនេះ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានសម្រេចបដិសេធបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ដែលបានស្នើសុំមោឃភាពចំពោះសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២។

ទន្ទឹមនឹងការសម្រេចតម្កល់សេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់បំភ្លឺអំពី ការយល់ច្រឡំទៅលើផលវិបាកផ្នែកនីតិវិធីនៃការបំបែកកិច្ចដំណើរការនីតិវិធីនិងបានសង្កត់ធ្ងន់ថា សំណុំរឿងដែលបានបំបែក គឺដាច់ដោយឡែកពីគ្នា ហើយថ្វីបើមានបណ្តុំភស្តុតាងរួមគ្នាតែមួយក្តី ក៏ការយល់ឃើញអំពីការទទួលខុសត្រូវព្រហ្មទណ្ឌមិនអាចផ្ទេរដោយស្វ័យប្រវត្តិពីសំណុំរឿងមួយទៅសំណុំរឿងមួយបានឡើយ។ ដោយទទួលស្គាល់អំពីលទ្ធភាពរបស់អង្គជំនុំជម្រះសាលាដំបូងដែលមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការចាត់ចែងនីតិវិធីទៅលើបទចោទនានាដែលមាននៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០២ នោះ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសព្យួរបទចោទទាំងនោះ។ ការព្យួរនេះមានលក្ខណៈបណ្តោះអាសន្នប៉ុណ្ណោះ ហើយអង្គជំនុំជម្រះតុលាការកំពូលបានជំរុញឲ្យអង្គជំនុំជម្រះសាលាដំបូងបំពេញករណីកិច្ចរបស់ខ្លួន ដើម្បីដោះស្រាយឲ្យបានអស់នូវសំណុំរឿងទាំងមូលចំពោះមុខខ្លួន។

ក្រោយពីចេញសេចក្តីសម្រេចនៅថ្ងៃនេះ សំណុំរឿង០០២/០២ មានបទចោទដែលពាក់ព័ន្ធដូចខាងក្រោម៖

- អំពើប្រល័យពូជសាសន៍លើជនជាតិចាម (និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនានៅក្នុងការផ្លាស់ទីលំនៅដោយបង្ខំទៅលើជនជាតិភាគតិចចាម) និងអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម

- ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងរំលោភសេពសន្ថវៈ នៅទូទាំងប្រទេស

- ការបោសសំអាតផ្ទៃក្នុង
- មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង មន្ទីរសន្តិសុខភ្នំក្រោល ការដ្ឋានទំនប់១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ការដ្ឋានទំនប់ត្រពាំងថ្ម និងសហករណ៍នានានៅត្រាំកក់
- ការប្រព្រឹត្តមកលើពុទ្ធសាសនិក (កម្រិតចំពោះសហករណ៍នានានៅត្រាំកក់តែប៉ុណ្ណោះ) និង
- ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ/ការប្រព្រឹត្តជាក់លាក់លើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (ដែលអនុវត្តកម្រិតចំពោះសហករណ៍នានានៅត្រាំកក់ ការដ្ឋានទំនប់១មករា មន្ទីរសន្តិសុខ ស-២១ និង មន្ទីរសន្តិសុខក្រាំងតាចាន់ តែប៉ុណ្ណោះ)។

វិសាលភាពនៃសវនាការនៃសំណុំរឿង ០០២/០២ ត្រូវបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤។ សំណុំរឿង ០០២/០២ គឺជាសំណុំរឿងទីពីរ ដែលមានប្រភពដើមមកពីដីកាដំណោះស្រាយនៃសំណុំរឿង ០០២។ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២។ វិសាលភាពនៃសំណុំរឿង ០០២/០១ ចូលជាស្ថាពរ ក្រោយពេលអង្គជំនុំជម្រះតុលាការកំពូលបដិសេធបណ្តឹងសាទុក្ខប្រឆាំងនឹងវិសាលភាពនៃបទចោទដែលកំណត់នៅក្នុងសេចក្តីសម្រេចសាជាថ្មីនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣។ សំណុំរឿងដែលបានបំបែកលើកទីមួយគឺសំណុំរឿង ០០២/០១។ សំណុំរឿងនេះផ្តោតជាបឋមទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដោយបង្ខំចេញពីភ្នំពេញ និងក្រោយមក ការជម្លៀសប្រជាជនដោយបង្ខំចេញពីតំបន់ផ្សេងៗទៀត (ដំណាក់កាលទី១ និងទី២) និងការសម្លាប់ទាហានសាធារណរដ្ឋខ្មែរនៅទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ ក្រោយពេលខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ ភ្លាម។ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០១ បានបញ្ចប់ទៅ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ ហើយអង្គជំនុំជម្រះសាលាដំបូងនឹងប្រកាសសាលក្រមលើសំណុំរឿងនេះ នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ នេះ។ ជនជាប់ចោទដែលត្រូវជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ និង០០២/០២ គឺ ខៀវ សំផន អតីតៈប្រធានគណៈប្រធានរដ្ឋ នៃកម្ពុជាប្រជាធិបតេយ្យ និង នួន ជា អតីតៈអនុលេខាបក្សកុំម្មុយនីស្តកម្ពុជា។

សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល លើបណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ អាចរកបាននៅលើគេហទំព័ររបស់ អ.វ.ត.ក:

http://www.eccc.gov.kh/en/node/30475

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ 0២៣
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh